វាយឡើងវិញជាភាសាខ្មែរពីឯកសារផ្លូវការ

ក្រសួងកសិកម្ម

ប្រកាសលេខ ១១១ ប្រក កសក/ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៨៩

ប្រកាសស្តីពីការតែងតាំង និង សកម្មភាពនាយកដ្ឋានសុរិយោដី

- បានឃើញរដ្ឋធម្មនុញ្ញ នៃរដ្ឋកម្ពុជា
- បានឃើញច្បាប់ស្តីពីអង្គការចាត់តាំង និងសកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៣ក្រ. ចុះ ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ ១៩៨២
- បានឃើញព្រះរាជក្រឹត្យលេខ ១៨ អនក្រ ចុះថ្ងៃទី២ ខែតុលា ឆ្នាំ១៩៨៤ ស្តីពីតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំង របស់ ក្រសួងកសិកម្ម
- បានឃើញអនុក្រឹត្យលេខ ៣១ អនក្រ ចុះថ្ងៃទី ១៤ ខែមីនា ឆ្នាំ១៩៨៩ ស្តីពីការផ្ទេរនាយកដ្ឋានគ្រប់គ្រងគោលនយោបាយ សេដ្ឋកិច្ចកសិកម្ម អោយទៅជានាយកដ្ឋានសុរិយោដី
- បានឃើញការចាំបាច់របស់ក្រសួងកសិកម្ម

**សំរេច**

មាត្រា ១ : នាយកដ្ឋានសុរិយោដី ជាអង្គភាពមួយនៅក្នុងបន្ទុកក្រសួងកសិកម្ម មានទីតាំងនៅក្រុងភ្នំពេញ មានតួនាទីជាសេនាធិការជំនួយអោយក្រសួងកសិកម្ម លើការងារគ្រប់គ្រង និងប្រើប្រាស់ដីធ្លី ទូទាំងប្រទេស ។

មាត្រា ២ : នាយកដ្ឋានសុរិយោដីមានប្រព័ន្ធគ្រប់គ្រងឯកភាពទូទាំងប្រទេស មានសិទ្ធិដឹកនាំ និងត្រួតពិនិត្យលើរាល់អង្គការចាត់តាំងសុរិយោដីពីមជ្ឈិមដល់មូលដ្ឋាន ។

មាត្រា ៣ : នាយកដ្ឋាន សុរិយោដីមានភារកិច្ចជាក់ស្តែងដូចខាងក្រោម :

១- សិក្សាស្រាវជ្រាវរាល់គោលការណ៍ គោលនយោបាយរបស់បក្ស និងរដ្ឋដើម្បីកសាងគំរោងលិខិតបទដ្ឋានទាំងឡាយ ដែលពាក់ព័ន្ធនឹងការគ្រប់គ្រង និងប្រើប្រាស់ដីធ្លីជូនថ្នាក់លើពិនិត្យ និងសំរេច ព្រមទាំងចាត់តាំង អនុវត្តអោយបានល្អ និងមានប្រសិទ្ធិភាព ។

២- កសាងទិសដៅផែនការ ដើម្បីបំរើការងារដែលជាកម្មវត្ថុ និងមុខសញ្ញានៃតួនាទី ភារកិច្ចរបស់នាយកដ្ឋាន សុរិយោដី ។

៣- កសាងបណ្តាឯកសារដែលពាក់ព័ន្ធនឹងការគ្រប់គ្រងប្រើប្រាស់ដីធ្លី ។ ពិនិត្យនឹងសំរេចលើរាល់បណ្តាឯកសារស្នើសុំកាន់កាប់ដីធ្លីក្នុង ក្របខ័ណ្ឌ និងសិទ្ធិអំណាចរបស់ខ្លួន ។

៤- ធ្វើការងារអភិរក្ស សុរិយោដី និងអធិការកិច្ចនៅក្នុងតួនាទី ភារកិច្ច និងសមត្ថរបស់នាយកដ្ឋាន សុរិយោដី ។

៥- អប់រំនយោបាយ សតិអារម្មណ បំពាក់បំប៉ន បណ្តុះបណ្តាលបច្ចេកទេស ដល់កម្មាអភិបាល បុគ្គលិក កម្មករ ។

៦- លើគំរោងកិច្ចសហប្រតិបត្តិការជាមួយបណ្តាប្រទេសលើវិស័យវិទ្យាសាស្ត្របច្ចេកទេស ។

៧- សហការជាមួយបណ្តាអង្គភាពនៅក្នុងបន្ទុកក្រសួងកសិកម្ម និងបណ្តាក្រសួងផ្សេងៗទៀតដែលមានពាក់ព័ន្ធក្នុងភារកិច្ចគ្រប់គ្រង និងប្រើប្រាស់ដីធ្លី ។

មាត្រា ៤ : អំពីរចនាសម័ន្ធចាត់តាំង របស់នាយកដ្ឋាន សុរិយោដី

វាយឡើងវិញជាភាសាខ្មែរពីឯកសារផ្លូវការ

**ក-ក្បាលម៉ាស៊ីនដឹកនាំ**

នាយកដ្ឋានសុរិយោដី ដឹកនាំដោយប្រធាន ១ រូប និងបណ្តាអនុប្រធានមួយចំនួនជំនួយការគឺ :

ប្រធាននាយកដ្ឋានសុរិយោដី ទទួលបន្ទុកដឹកនាំរួម ទទួលបន្ទុកផ្ទាល់ដោយឡែកការងារមួយចំនួន ទទួលខុសត្រូវលើរាល់សភាពការណ៍នៃការងាក្នុងនាយកដ្ឋាន សុរិយោដីចំពោះមុខរដ្ឋមន្ត្រីក្រសួងកសិកម្ម។ ប្រធាននាយកដ្ឋានសុរិយោដីអនុវត្តសិទ្ធិដឹកនាំតាមរបបប្រធានដែលបានកំណត់ លើមូលដ្ឋាននេះ ត្រូវពង្រឹងពង្រីកអោយបានល្អ របបមូលភាពដឹកនាំជាក់ស្តែងប្រធាននាយកដ្ឋានសុរិយោដី មានភារកិច្ចចាត់ចែងការងារ នយោបាយ សង្គមកិច្ច សេដ្ឋកិច្ច បច្ចេកទេស ចាត់តាំងក្បាលម៉ាស៊ីនបណ្តាផ្នែក នៅចំណុះការិយាល័យ និងចេញសេចក្តីសំរេច ក្នុងសិទ្ធិអំណាចជាប្រធាននាយកដ្ឋាន សុរិយោដី ដោយឡែកចំពោះការងារកម្មាភិបាល ត្រូវស្ថិតនៅក្នុងមូល ភាពថ្នាក់ដឹកនាំនាយកដ្ឋានពិនិត្យ និងសំរេច ដោយមានការចូលរួមមតិពីអង្គការចាត់តាំងបក្ស និងអង្គការចាត់តាំងអង្គការមហាជន នៅក្នុង មូលដ្ឋាន ។

បណ្តាអនុប្រធាននាយកដ្ឋាន ជាជំនួយការអោយប្រធាននាយកដ្ឋាន ត្រូវបានប្រធានបែងចែកប្រគល់ការងារមួយចំនួនអោយទទួលបន្ទុកត្រួវរាយការណ៍ និងទទួលការណែនាំពីប្រធានហើយ និងទទួលខុសត្រូវចំពោះមុខប្រធាន លើរាល់សភាពការណ៍ក្នុងការងារដែលបានបែងចែកប្រគល់អោយទទួលបន្ទុក ទន្ទឹមនេះ ក៏រួមជាមួយប្រធាន ទទួលខុសត្រូវលើរាល់សភាពការណ៍នៃការងារ ក្នុងនាយកដ្ឋានចំពោះមុខរដ្ឋមន្ត្រីក្រសួងកសិកម្ម ។

**ខ- ក្បាលម៉ាស៊ីនចាត់តាំង :**

បណ្តាការិយាល័យសេនាធិការជំនួយការផ្ទាល់របស់នាយកដ្ឋាន សុរិយោដីមាន៥ គឺ

១- ការិយាល័យ រដ្ឋបាល និងចាត់តាំង

២- ការិយាល័យ ផែនការ និងគណនេយ្យ

៣- ការិយាល័យកិច្ចការថ្មី

៤- ការិយាល័យ អភិរក្ស សុរិយោដី

៥- ការិយាល័យ អធិការកិច្ចភូមិបាល ។

តួនាទី ភារកិច្ច និរចនាសម្ព័ន្ធចាត់តាំងរបស់បណ្តាការិយាល័យនៅចំណុះនាយកដ្ឋានសុរិយោដី ត្រូវសំរេចដោយប្រធាននាយកដ្ឋាន សុរិយោដីដោយឡែកប្រធាន អនុប្រធានការិយាល័យត្រូវសំរេចតែងតាំង ឬ បញ្ឈប់ដោយរដ្ឋមន្ត្រី ក្រសួងកសិកម្ម ។

នាយកដ្ឋាន សុរិយោដី មានបណ្តាញអង្គការចាត់តាំង សុរិយោដី ធ្វើសកម្មភាពនៅតាមមូលដ្ឋាន ខេត្ត ក្រុង ស្រុក ខ័ណ្ឌ ជាជំនួយការដល់នាយកដ្ឋាន សុរិយោដី គឺ:

- នៅខេត្ត-ក្រុងមានការិយាល័យសុរិយោដីខេត្ត-ក្រុងមានថ្នាក់ស្មើការិយាល័យ នៅចំណុះនាយកដ្ឋាននៃក្រសួងមន្ទីរជុំវិញមជ្ឈិមដែលសំរេចចាត់តាំងបង្កើត ឬរំសាយចោលដោយរដ្ឋមន្ត្រីក្រសួង កសិកម្ម ។ ការិយាល័យសុរិយោដីខេត្ត ក្រុងដឹកនាំដោយ ប្រធាន១ រូប និងបណ្តាអនុប្រធានមួយចំនួនជំនួយការ ដែលសំរេចតែងតាំង ឬបញ្ឈប់ដោយរដ្ឋមន្ត្រីក្រសួងកសិកម្ម ដោយមាន ការស្តាបស្ទង់យោបល់ពីមូលដ្ឋាន ។
- នៅស្រុក-ខ័ណ្ឌមានការិយាល័យភូមិបាលស្រុក-ខ័ណ្ឌមានថ្នាក់ស្មើការិយាល័យហើយនៅចំណុះគណ:កម្មាធិការប្រជាជនស្រុក-ខ័ណ្ឌដែលសំរេចចាត់តាំង ឬរំសាយចោលដោយរដ្ឋមន្ត្រីក្រសួងកសិកម្ម ។ ការិយាល័យភូមិបាលស្រុក-ខ័ណ្ឌដឹកនាំ ដោយប្រធាន ១រូប និងបណ្តាអនុប្រធានមួយចំនួនជំនួយការ ដែលសំរេចតែងតាំង ឬ បញ្ឈប់ដោយរដ្ឋមន្ត្រីក្រសួងកសិកម្ម ដោយមានការ ស្តាបស្ទង់យោបល់ពីមូលដ្ឋាន ។

វាយឡើងវិញជាភាសាខ្មែរពីឯកសារផ្លូវការ

មាត្រា ៥ : តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំង របស់ការិយាល័យ សុរិយោដីខេត្ត ក្រុង និងការិយាល័យភូមិបាលស្រុក-ខ័ណ្ឌ អាស្រ័យដោយប្រធាននាយកដ្ឋាន សុរិយោដីពិនិត្យសំរេច ដោយមានមតិឯកភាពពីក្រសួងកសិកម្ម ។

មាត្រា ៦: អង្គការចាត់តាំង សុរិយោដី នៅមូលដ្ឋាន ត្រូវស្ថិតនៅក្រោមការដឹកនាំផ្នែករដ្ឋបាល និងនយោបាយ សតិអារកម្មណ៍ របស់ មូលដ្ឋាន។

មាត្រា ៧: ក្របខ័ណ្ឌរបស់អង្គការចាត់តាំង សុរិយោដី ទាំងអស់ជាក្របខ័ណ្ឌរបស់នាយកដ្ឋាន សុរិយោដី ដែលត្រូវបានក្រសួងកសិកម្ម សំរេចកំណត់បែងចែកប្រគល់អោយរាល់អង្គការចាត់តាំងទាំងនោះ យកទៅប្រើប្រាស់ ដោយយោងតាមសំណើររបស់ប្រធាននាយកដ្ឋានសុរិយោដី ។

មាត្រា ៨ : គណៈកម្មាធិការប្រជាជន ខេត្ត ក្រុង មន្ទីរនាយកដ្ឋានចាត់តាំង និងកម្មាភិបាលនាយកដ្ឋាន សុរិយោដីគ្រប់អង្គភាពក្នុងបន្ទុកក្រសួងកសិកម្មមានភារកិច្ចអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃដែលបានចុះហត្ថលេខាតទៅ ។